00686983

E78/1

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសារណារបស់ អៀង សារី ស្នើសុំឲ្យច្រានចោលចម្លើយទាំងអស់របស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ក្នុងករណីដែលគាត់មិនផ្តល់សក្ខីកម្ម ព្រមទាំងស្នើសុំឲ្យបញ្ជាក់អត្តសញ្ញាណបន្ថែមទៀតនៃភស្តុតាងដោះបន្ទុក**

---

**<u>អ្នកដាក់ឯកសារ:</u>**

**សហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង

លោក Andrew CAYLEY

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**<u>អ្នកទទួលឯកសារ:</u>**

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រមJean-Marc LAVERGNE

ចៅក្រម ធូ មណី

**<u>ចម្លងជូន:</u>**

**ជនជាប់ចោទ:**

នួន ជា

អៀង សារី

អៀង ធីរិទ្ធ

ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor Koppe

**ឯកសារដើម**

DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 10 / 05 / 2011

ម៉ោង (Time/Heure): 15 : 30

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក ស សូវាន
លោក Jacques VERGÈS
លោក Phillipe GRECIANO

## I. ចម្លើយតប

១. កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១១ អៀង សារី តាមរយៈមេធាវីការពារក្ដីរបស់ខ្លួន ("មេធាវីការពារក្ដី") បានដាក់ "សារណារបស់ខ្លួន ស្នើសុំមិនឱ្យទទួលយកនូវរាល់ចម្លើយទាំងអស់របស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច"ជាភស្តុតាង លុះត្រាតែ ឌុច បង្ហាញខ្លួននៅក្នុងតុលាការក្នុងនាមជាសាក្សី ព្រមទាំងស្នើសុំឱ្យ ក.ស.ព និងអង្គជំនុំជម្រះសាលាដំបូង បង្ហាញនូវចម្លើយមិនពិតនានារបស់ ឌុច"[1] ("សារណា")។ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ សហព្រះ រាជអាជ្ញា[2] បានស្នើសុំទៅ អង្គជំនុំជម្រះសាលាដំបូង ឱ្យកោះហៅ ឌុច ដើម្បីឱ្យមកធ្វើជាសាក្សីនៅក្នុងសវនាការជំនុំជម្រះក្ដី សារណានេះគួរតែត្រូវបានធ្វើការបដិសេធចោល ដោយផ្អែកលើមូលដ្ឋានថា វាមុនពេលពេក[3]។

២. ក្នុងករណីបើ ឌុច ផ្ដល់សក្ខីកម្មនៅក្នុងសវនាការជំនុំជម្រះក្ដី មេធាវីការពារក្ដីស្នើសុំបន្ថែមឱ្យសហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះសាលាដំបូង បង្ហាញនូវរាល់ករណីទាំងអស់ដែល ក.ស.ព និងអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឌុចមិនបង្ហាញការពិតក្នុងចម្លើយរបស់គាត់ ក្នុងសំណុំ

---

[1] ឯកសារលេខ E78, ដែលមានចំណងជើងថា "សារណារបស់ខ្លួនស្នើសុំមិនឱ្យទទួលយកនូវរាលចម្លើយទាំងអស់របស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច"ជាភស្តុតាង លុះត្រាតែ ឌុច បង្ហាញខ្លួននៅក្នុងតុលាការក្នុងនាមជាសាក្សី ព្រមទាំងស្នើសុំឱ្យ កសព និងអង្គជំនុំជម្រះសាលាដំបូង បង្ហាញនូវចម្លើយមិនពិតនានារបស់ ឌុច", ចុះថ្ងៃទី២៦ មេសា២០១១, ERN 00658712-00658722។

[2] សូមអាន ឧបសម្ពន្ធទី១ដែលភ្ជាប់ជាមួយឯកសារលេខ E9/4 , ដែលមានចំណងជើងថា " បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០នៃវិធានផ្ទៃក្នុង ដែលរួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១ទី២, ទី៣,ទី៣ក,ទី៤, និងទី៥"។ ឯកសារលេខ E9/4.1 , "ឧបម្ព័ន្ធទី១ ០: លំដាប់លេខរៀងនៃការចូលបង្ហាញខ្លួនរបស់សាក្សីនៅក្នុងពេលសវនាការ ដែលបាន ស្នើសុំ", ចុះថ្ងៃទី២៨ មករា ២០១១, លេខ ERN 00640705-006407013, ត្រង់ទំព័រ៤។

[3] ដូចដែលបានបញ្ជាក់ដោយ សហព្រះរាជអាជ្ញា នៅក្នុងអង្គប្រជុំស្ដីពីការរៀបចំសវនាការ កាលពីថ្ងៃទី៥ មេសា ២០១១ ថា នឹងមានការដាក់សារណាអំពីអង្គច្បាប់មួយស្ដីពីបញ្ហាភាពអាចទទួលយកបាននៃចម្លើយនានា ដោយអ្នកធ្វើចម្លើយទាំងនោះមិនបាច់ចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេ។ សូមមើលឯកសារ E1/2.1 "ប្រតិចារឹកអំពីការប្រជុំរៀបចំសវនាការ-ការបិទការប្រជុំនៅក្នុងសំណុំរឿង០០២/១៩-០៩-២០០៧ អវតក/អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១, ERN00664215-00664345 នៅទំព័រ៨៦-៨៨។

រឿងលេខ០០១ [4]។ ឆ្លងតាម ចម្លើយ និងសេចក្តីយោងទាំងនោះ ត្រូវបានបញ្ជាក់នៅក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់ជាសាធារណៈ និងការសួរសំនួរដល់ ឌុច នៅឯសវនាការរបស់គាត់ សហព្រះរាជអាជ្ញា បញ្ជាក់ថា ខ្លួនមិនរក្សាទុកនូវបញ្ជីចម្លើយដទៃទៀតរបស់ ឌុច ដែលខ្លួនចាត់ទុកថា ចម្លើយទាំងនោះមិនពិតនោះទេ។ សេចក្តីយោងទាំងនេះ បានផ្តល់នូវការជូនដំណឹងច្បាស់លាស់រួចហើយ ដល់មេធាវីការពារក្តី អំពីការវាយតម្លៃរបស់សហព្រះរាជអាជ្ញា ទៅលើភាពគួរឱ្យជឿទុកចិត្តបានរបស់ ឌុច និងទៅលើចម្លើយជាក់លាក់នានាផ្ទាល់តែម្តង។ ការណ៍នេះនឹងបានជាជំនួយដល់មេធាវីការពារក្តី និងដល់ភាគីដទៃទៀតនៅក្នុងការត្រៀមរៀបចំដើម្បីពិនិត្យទៅលើរូបគាត់។

៣. គ្រប់ករណីទាំងអស់ បញ្ហាស្តីពីកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា ដែលត្រូវបង្ហាញអំពីឯកសារដោះបន្ទុក ត្រូវបានបញ្ជាក់ច្បាស់លាស់ ដោយអង្គជំនុំជម្រះសាលាដំបូងរួចហើយ ដែលនៅក្នុងនោះមានមួយផ្នែកធំ ធ្វើឱ្យសារណានេះមានលក្ខណៈច្រំដែល ចំពោះសំណើសុំឱ្យបង្ហាញពី អត្តសញ្ញាណនៃឯកសារដោះបន្ទុកបន្ថែមទៀត ។ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការបញ្ជាក់រួចហើយអំពីកាតព្វកិច្ចក្នុងការបង្ហាញនេះ ក៏ដូចជាការគូសបញ្ជាក់ផងដែរអំពីព្រំដែនកំណត់របស់វា៖

“**បានធ្វើការបញ្ជាក់អំពីថា តើសហព្រះរាជអាជ្ញាត្រូវមានកាតព្វកិច្ច ដាក់ទាំងឯកសារដាក់បន្ទុកផង និងទាំងឯកសារដោះបន្ទុកផង នៅក្នុងបញ្ជីឯកសារ/វត្ថុតាងនានា ដែរឬទេ?**។ ក្នុងសំណុំរឿងមានឯកសារនានាដែលត្រូវបានគេប្រមូលកាលពីក្នុងអំឡុងពេលធ្វើកិច្ចស៊ើបសួរ ដែលឯកសារទាំងនេះអាចជាឯកសារដាក់បន្ទុក ឬដោះបន្ទុក។ ឯកសារទាំងនេះបើកសិទ្ធិឱ្យគ្រប់ភាគីទាំងអស់ និងចៅក្រមនានាអាចពិនិត្យមើលបាន។ <u>សហព្រះរាជអាជ្ញាមិនចាំបាច់ត្រូវធ្វើការបញ្ជាក់ថា តើ</u>

[4] សារណា ទំព័រ ១

<u>ឯកសារណាខ្លះក្នុងចំណោមឯកសារទាំងនេះដែលខ្លួនចាត់ទុកថា ជាឯកសារដោះបន្ទុកនោះទេ តែមេធាវីការពារក្តីជាអ្នកធ្វើការវាយតម្លៃថាតើឯកសារណាខ្លះដែលទាក់ទងនឹងជនជាប់ចោទ</u>។ សហព្រះរាជអាជ្ញាត្រូវដាក់បញ្ជីឯកសារ/វត្ថុតាងទាំងនេះរបស់ខ្លួន ដែលខ្លួនយល់ឃើញថាមានការពាក់ព័ន្ធ នៅថ្ងៃទី១៩ ខែមេសា ហើយមិនចាំបាច់ត្រូវធ្វើការបញ្ជាក់ថា តើឯកសារទាំងនេះជាឯកសារដាក់បន្ទុក ឬដោះបន្ទុកនោះឡើយ។ ទោះជាយ៉ាងណាក្តី បើសិនជា សហព្រះរាជអាជ្ញាមាននៅក្នុងដៃរបស់ខ្លួននូវឯកសារផ្សេងៗ ដែលមិនអាចរកជាសាធារណៈបាន និងឯកសារនោះមិនស្ថិតនៅក្នុងសំណុំរឿង គឺសហព្រះរាជអាជ្ញាមានកាតព្វកិច្ចត្រូវតែដាក់បញ្ចូលទៅក្នុងបញ្ជីរបស់ខ្លួននូវឯកសារថ្មីទាំងអស់ ដែលនាំទៅរកការបង្ហាញការពិត ហើយទោះបីជាដាក់ បន្ទុក ឬដោះបន្ទុកក៏ដោយ។ ក្រុមមេធាវីការពារក្តីក៏ត្រូវដាក់បញ្ជីឯកសារ/វត្ថុតាងរបស់ពួកគេផងដែរ នៅត្រឹមថ្ងៃទី១៩ ខែមេសានេះ ស្របទៅតាមការណែនាំកាលពីមុននេះ ដែលនឹងជួយយ៉ាងធំធេងដល់អង្គជំនុំជម្រះក្នុងភារកិច្ចដែលខ្លួនត្រូវតែធ្វើការថ្លឹងថ្លែងឱ្យបានគ្រប់គ្រាន់នូវរាល់ឯកសារទាំងអស់ដែលខ្លួនចាត់ទុកថា ជាឯកសារដោះបន្ទុក”[5]។

៤. អាស្រ័យហេតុនេះ គឺជាការច្បាស់លាស់ និងត្រូវបានទទួលយល់ព្រមហើយដែរ ថាសហព្រះរាជអាជ្ញាមានភារកិច្ចក្នុងការបង្ហាញជូនដល់មេធាវីការពារក្តី នូវព័ត៌មានទាក់ទងអំពីឯកសារដោះបន្ទុកដែលខ្លួនមាននៅក្នុងដៃ ក៏ប៉ុន្តែមិនរហូតទៅដល់ការរៀបចំសំណួរសម្រាប់សួរសាក្សីឱ្យមេធាវីការពារក្តីរបស់ អៀង សារី នោះឡើយ។ នៅពេលដែលព័ត៌មានទាក់ទងនឹងឯកសារដោះបន្ទុកដែលមានសក្តានុពលស្ថិតនៅក្នុងដៃរបស់មេធាវីការពារក្តី គឺពួកគេជាអ្នកស្ថិតនៅក្នុងស្ថានភាពដ៏ប្រសើរបំផុត ដើម្បីធ្វើការកំណត់ថា តើត្រូវភ្ជាប់នូវទម្ងន់ត្រឹមណាទៅនឹងព័ត៌មាននេះ ជាពិសេស

---

[5] ឯកសារ លេខៈE9/25.1.1 សារអេឡិចត្រូនិចរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា “ចម្លើយតបទៅនឹងសំណួរដែលបានធ្វើឡើងនៅអំឡុងអង្គប្រជុំរៀបចំសវនាការ” ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ នៅទំព័រENR00665531។

នៅពេលដែលពួកគេមានផ្លូវតែមួយគត់ ដើម្បីចូលទៅប្រាស្រ័យជាមួយជនជាប់ចោទ មិនដូចសហព្រះរាជអាជ្ញានោះទេ។

៥. នៅក្នុងសារណារបស់ពួកគេ មេធាវីការពារក្ដីបានរំលឹកដល់ សហព្រះរាជអាជ្ញា ថាខ្លួនមិនផ្ដល់ភ័ស្តុតាងណាដែលខ្លួនដឹងថាមិនពិតនោះទេ[6]។ ជាការពិតហើយ នេះគឺជាកាតព្វកិច្ចដែលត្រូវអនុវត្តចំពោះគ្រប់ភាគីទាំងអស់នៅក្នុងសវនាការ ដែលរួមទាំងមេធាវីការពារក្ដីផងដែរ។ ជាការច្បាស់លាស់ណាស់ថា នេះគឺសម្រាប់ទាំងកាតព្វកិច្ចខាងផ្លូវច្បាប់ និងទាំងកាតព្វកិច្ចខាងក្រមសីលធម៌សម្រាប់មេធាវីគ្រប់រូបនៅពេលចូលបង្ហាញខ្លួនចំពោះមុខតុលាការ។ ដើម្បីឱ្យបានច្បាស់ នៅក្នុងករណីនេះ សហព្រះរាជអាជ្ញាមិនស្នើសុំឱ្យ ឌុច ផ្ដល់សក្ខីកម្មលើបញ្ហានានាដែលខ្លួនជឿថា ឌុច មិនផ្ដល់ការពិតនោះទេ ប៉ុន្តែគ្រាន់តែចំពោះបញ្ហាទាំងឡាយដែលខ្លួនជឿថានឹងជួយដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការការបង្ហាញការពិតនៅក្នុងករណីរឿងនេះតែប៉ុណ្ណោះ។ ប្រការដែលសច្ចសីលភាព របស់ ឌុច ដូចដែលមាននៅក្នុងចម្លើយពីមុនៗរបស់គាត់ ស្ដីពីតួនាទីរបស់ ខ្លួនគាត់ផ្ទាល់នៅមន្ទីរស-២១ ដែលត្រូវបានគេចោទសួរនោះ គឺចម្លើយទាំងនោះមិនបង្កើតទៅជា ការ សង្ស័យអំពីសច្ចសីលភាពលើចម្លើយនានារបស់គាត់ ដែលទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តគោលនយោបាយដែលកំពុងអនុវត្តនាពេលនោះ និងតួនាទីផ្សេងៗរបស់ អៀង សារី និងជនជាប់ ចោទដទៃទៀត ដូចដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ។ ហេតុនេះ សហព្រះរាជអាជ្ញាគ្រាន់តែស្វែងរកសុំការផ្ដល់សក្ខីកម្មពី ឌុច និងពឹងផ្អែកលើផ្នែកខ្លះៗ នៃចម្លើយ កាលពីមុនៗ របស់គាត់ ដែលសហព្រះរាជអាជ្ញាជឿថា ប្រកបដោយការពិតតែប៉ុណ្ណោះ។

៦. តាមការជូនដំណឹងដែលសហព្រះរាជអាជ្ញាបានផ្ដល់ជូនទៅមេធាវីការពារក្ដី អំពីភាពគួរឱ្យជឿទុកចិត្តរបស់ ឌុច និងប្រការដែលថាមេធាវីការពារក្ដីក៏មាន នូវព័ត៌មានដែលដូចគ្នានឹងព័ត៌មានរបស់

[6] សារណា ទំព័រ៧

សហព្រះរាអាជ្ញា និងអង្គជំនុំជម្រះសាលា ដំបូងដែរនោះ ហើយជាសំខាន់ មេធាវីការពារក្តីមានឱកាសជួបជនជាប់ចោទដែលមានតួនាទីសំខាន់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នោះតាមពិតមេធាវីការពារក្តីឋិតក្នុងស្ថានភាពល្អមួយ ដើម្បីកំណត់ការពិតនៃចម្លើយពីមុនៗមករបស់ ឌុច។

## II. ដំណោះស្រាយដែលស្នើឡើង

៧. អាស្រ័យដោយមូលហេតុដូចបានលើកឡើងខាងលើនេះ សហព្រះរាជអាជ្ញាស្នើថា សារណា នេះត្រូវបដិសេធចោល ដោយសារធ្វើឡើងមុនពេលពេកដោយគ្មានមូលដ្ឋានខាងអង្គច្បាប់ ឬអង្គសេចក្តីដែលទាក់ទងទៅនឹងអង្គហេតុ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ | លោក យ៉េត ចរិយា<br>សហព្រះរាជអាជ្ញារង | | |
| | លោក Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |